# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាល

# គោលនយោបាយជាតិ

# ស្ដីពី

# ការសិក្សាពេញមួយជីវិត

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

ការអប់រំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សនិងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអប់រំតាមគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ ជាមធ្យោបាយសក្តិសិទ្ធិក្នុងការធានាឱ្យការសិក្សាមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ការសិក្សាពេញមួយជីវិតបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំ សំដៅធានាសិទ្ធិ សេរីភាព និងសុភមង្គល បុគ្គល គ្រួសារ និងសង្គម ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មី។ ការសិក្សាពេញមួយជីវិតជាដំណើរការរៀនសូត្រទាំងនៅក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ តាំងពីការចាប់កំណើតរហូតដល់វ័យជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា ឱ្យក្លាយជាពលរដ្ឋល្អនិងចេះរួមរស់ជាមួយគ្នាប្រកបដោយភាពសុខដុមនៅក្នុងសង្គម។ ស្ថិតក្នុងបរិការណ៍នៃសកលភាវូបនីយកម្មសតវត្សរ៍ទី២១និងការប្រកួតប្រជែងទាំងក្នុងតំបន់ និងសកលលោក ផ្នែកសង្គម សេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ ឧស្សាហកម្ម និងបច្ចេកវិទ្យា បុគ្គលគ្រប់រូបត្រូវទទួលបានការបណ្តុះបណ្តាលវប្បធម៌សិក្សាពេញមួយជីវិត។

នៅក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ ព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ជាពិសេស ការធានាបាននូវសន្តិភាពពេញលេញ ស្ថិរភាពនយោបាយរឹងមាំ និងសន្តិសុខសាធារណៈ ជាមួយនឹងកំណើនសេដ្ឋកិច្ចជាមធ្យម៧,៧ភាគរយក្នុងមួយឆ្នាំ។ អត្រានៃភាពក្រីក្រធ្លាក់ចុះមកក្នុងរង្វង់១០ភាគរយ នៅឆ្នាំ២០១៨។ បច្ចុប្បន្ននេះ កម្ពុជាកំពុងបោះជំហានទៅរកដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍ គឺការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ នៅក្នុងន័យនេះ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិតត្រូវបានអភិវឌ្ឍឡើង ដើម្បីឆ្លើយតបទៅនឹងបរិបទថ្មី សំដៅអភិវឌ្ឍធនធានមនុស្សប្រកបដោយសក្តានុពលសម្រាប់ឈានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាខាងលើ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មទាំងផ្នែកស្មារតី បច្ចេកទេស និងសម្ភារៈ ធ្វើឱ្យសម្រេចបាននូវគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត សម្រាប់ជាត្រីវិស័យក្នុងការអភិវឌ្ឍធនធានមនុស្សឆ្ពោះទៅកាន់វឌ្ឍនភាព វិបុលភាព និងភាពថ្កើងថ្កានរុងរឿង។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន សហគមន៍ គ្រួសារ និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួមចំណែកក្នុងការផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលនយោបាយនេះឱ្យទទួលបានជោគជ័យ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៩

**ហ៊ុន សែន**

## មាតិកា


**អារម្ភកថា** ............ i

**១. សេចក្តីផ្តើម** ............ ១

**២. ចក្ខុវិស័យ** ............ ៤

**៣. គោលបំណង** ............ ៤

**៤. គោលដៅ** ............ ៤

**៥. យុទ្ធសាស្ត្រ** ............ ៤

៥.១. អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ ............ ៤

៥.២. ផ្តល់សេវាការសិក្សាពេញមួយជីវិតដល់ពលរដ្ឋគ្រប់រូប ............ ៥

៥.៣. អភិវឌ្ឍកម្មវិធីសិក្សាពេញមួយជីវិតឱ្យសម្បូរបែបនិងមានភាពបត់បែនឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សា ............ ៥

៥.៤. អភិវឌ្ឍមជ្ឈមណ្ឌលសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងទីកន្លែងសិក្សាឱ្យបានសមស្រប... ៦

៥.៥. បណ្តុះបណ្តាលអ្នកសម្របសម្រួលកម្មវិធីសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាជីវៈ...៦

៥.៦. ផ្តល់ការទទួលស្គាល់ ការបញ្ជាក់សុពលភាព និងមានការទទួលស្គាល់គុណភាពនៃការសិក្សាពេញមួយជីវិតដោយតម្លាភាព យុត្តិធម៌ និងមានសង្គតិភាព ............ ៧

៥.៧. ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់គាំទ្រការសិក្សាពេញមួយជីវិត ............ ៧

៥.៨. លើកកម្ពស់វប្បធម៌រស់នៅជាពលរដ្ឋសកល ............ ៨

៥.៩. លើកកម្ពស់សមភាព សមធម៌ យេនឌ័រ និងបរិយាបន្ន ............ ៨

៥.១០. លើកកម្ពស់ការអប់រំតាមប្រព័ន្ធបច្ចេកវិទ្យា ............ ៨

៥.១១. ជំរុញវិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមផ្តល់សេវាសិក្សាពេញមួយជីវិត ............ ៩

**៦. ផែនការសកម្មភាព** ............ ៩

៦.១. ការបង្កើតយន្តការ ............ ៩

៦.២. ការបង្កើតក្របខណ្ឌគតិយុត្ត ............ ៩

៦.៣. ការគាំទ្រហិរញ្ញវត្ថុ ............ ១០

៦.៤. ការបណ្តុះបណ្តាលធនធានមនុស្ស ............ ១០

៦.៥. ដំណើរការអនុវត្តគម្រោង ............ ១០

**៧. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ** ............ ១០

**៨. សេចក្តីសន្និដ្ឋាន** ............ ១១

**សន្ទានុក្រម**

## ១. សេចក្តីផ្តើម

បញ្ញត្តិនៃ **«ការសិក្សាពេញមួយជីវិត»** ឆ្នាំ១៩៧២ ជាបញ្ញត្តិគោលមួយដែលបានដាក់បញ្ចូលទៅក្នុងគោលនយោបាយអប់រំរបស់ប្រទេសជឿនលឿននិងប្រទេសកំពុងអភិវឌ្ឍ។ តាមរយៈបញ្ញត្តិនៃការសិក្សាពេញមួយជីវិតនេះ បានលេចឡើងនូវបញ្ហាប្រឈមមួយចំនួនដូចជា សិទ្ធិទទួលបានការអប់រំ ការចុះឈ្មោះចូលរៀន និងគុណភាពអប់រំ ដែលមិនទាន់ឆ្លើយតបនឹងការវិវត្តរបស់ពិភពលោក (ការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ១៩៩០ នៅជមទៀន ប្រទេសថៃ)។ គោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា ត្រូវបានពិនិត្យឡើងវិញក្នុងឆ្នាំ២០០០ នៅដាកា ប្រទេសសេណេហ្គាល់ ស្របពេលដែលប្រទេសជឿនលឿនបានផ្តោតលើការអប់រំជនពេញវ័យអំពីជំនាញវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។

ក្នុងសតវត្សទី២១នេះ ការសិក្សាពេញមួយជីវិតបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំ ហើយក៏ជាឧបករណ៍ដែលមានប្រយោជន៍សម្រាប់ទទួលបានសិទ្ធិសេរីភាព ភាពសប្បាយរីករាយ និងឆ្លើយតបទៅនឹងបម្រែបម្រួលនៃតម្រូវការទីផ្សារការងារ ពិសេស ភាពចាំបាច់នៃការសិក្សារបស់ពលរដ្ឋគ្រប់រូបនៅគ្រប់កាលៈទេសៈផងដែរ។ ការសិក្សាពេញមួយជីវិតបានក្លាយជាសមាសភាគសំខាន់ក្នុងគោលដៅទី៤នៃក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ នៅអ៊ីនឈន់ សាធារណរដ្ឋកូរ៉េ ពោលគឺ «ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា»។

ចាប់តាំងពីចុងឆ្នាំ២០១៥ តាមរយៈកិច្ចប្រជុំថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអប់រំ ឆ្នាំ២០៣០ ដែលរៀបចំដោយអង្គការយូណេស្កូ ប្រទេសនីមួយៗបានរៀបចំពិនិត្យឡើងវិញ និងធ្វើមូលដ្ឋានីយកម្មលើគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររបស់ខ្លួន ឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ស្ថិតក្នុងបរិបទនេះ ប្រទេសមួយចំនួនក្នុងតំបន់បាននិងកំពុងរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការសិក្សាពេញមួយជីវិតនៅកម្រិតផ្សេងៗគ្នា។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៦៥ បានចែងថា «រដ្ឋត្រូវការពារនិងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប» និងមាត្រា៦៦ «រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការនិងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត»។

រាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែង ផ្តល់ឱកាសតាមគ្រប់រូបភាពដល់ប្រជាជនកម្ពុជាគ្រប់រូប ដើម្បីទទួលបានការអប់រំទាំងអស់គ្នា ដោយបើកយុទ្ធនាការរំដោះគ្រោះមិនចេះអក្សរនិងគ្រោះភ្លេចអក្សរ តាមពាក្យស្លោកមួយចំនួនក្នុងន័យលើកកម្ពស់ការអប់រំដូចជា«អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ» ក្នុងទសវត្សរ៍ទី៩នៃសតវត្សន៍ទី២០ និង«រៀនហើយរៀនទៀត រៀនមិនចេះចប់» នៅទសវត្សរ៍ទី១០នៃសតវត្សន៍ទី២០។ ដំណាក់កាលបន្តបន្ទាប់ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីអប់រំពាក់ព័ន្ធនានា មានជាអាទិ៍ច្បាប់ស្តីពីការអប់រំ គោលនយោបាយអប់រំក្រៅប្រព័ន្ធនិងផែនការជាតិអប់រំក្រៅប្រព័ន្ធ ដើម្បីឆ្លើយតបនឹងតម្រូវការគ្រប់ក្រុមមុខសញ្ញាជនបាត់បង់ឱកាស។

នៅពេលបច្ចុប្បន្ននេះ ប្រព័ន្ធអប់រំកម្ពុជាមានការរីកចម្រើនខាងបរិមាណគួរជាទីមោទនៈជាពិសេស នៅកម្រិតបឋមសិក្សា។ ទោះបីជាយ៉ាងនេះក្តី បញ្ហាសិស្សបោះបង់ការសិក្សានិងគុណភាពសិក្សានៅតែជាក្តីកង្វល់នៅឡើយ។ ជាក់ស្តែង អត្រាពិតនៃការសិក្សានៅបឋមសិក្សាមានប្រមាណ៩៧% នៅទសវត្សរ៍ចុងក្រោយនេះ។ ប៉ុន្តែ សិស្សដែលអាចបញ្ចប់ការសិក្សានៅបឋមសិក្សាមានប្រមាណ៨០% បញ្ចប់មធ្យមសិក្សាបឋមភូមិមានប្រមាណ៤០% និងមធ្យមសិក្សាទុតិយភូមិមានប្រមាណ២០%។ ការវាយតម្លៃថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យាក៏បានបង្ហាញផងដែរថា សិស្សស្ទើរតែពាក់កណ្តាលដែលបានចូលរួមក្នុងការវាយតម្លៃនៅថ្នាក់ទី៣ ទី៦ និងទី៨ មិនទទួលបានចំណេះដឹងដូចការរំពឹងទុកនោះទេ។

ដោយសារមានការខិតខំពីគ្រប់ភាគីតាមរយៈកម្មវិធីអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ អត្រាអក្ខរកម្មជនពេញវ័យអាយុ១៥ឆ្នាំឡើងមាន៨០,៥% ស្ត្រីមាន៧៥,០% ក្នុងនោះអត្រាអក្ខរកម្មនៅតាមជនបទ មានត្រឹមតែ៧៦,៨% ស្រី៧០,៧% ប៉ុណ្ណោះ(អង្កេតស្តីពីសេដ្ឋកិច្ចសង្គមកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ២០១៦)។

ផលិតភាពរបស់និយោជិតនៅតាមសហគ្រាស គ្រឹះស្ថានត្រូវបានកត់សម្គាល់ដោយនិយោជកថានៅមានកម្រិត ដោយសារតែក្នុងចំណោមកម្លាំងពលកម្មអាយុ១៥ឆ្នាំដល់៦៤ឆ្នាំសរុប៨ ៣៥៩ ០០០នាក់ ស្រី៤ ០៣៥ ០០០នាក់ ក្នុងចំណោមនោះ កម្លាំងពលកម្មដែលមិនបានចូលរៀនសាលាសោះឬបានចូលរៀនតិចតួច ហើយបោះបង់ការសិក្សាមាន១៣,៥០ភាគរយមិនបានបញ្ចប់ថ្នាក់បឋមសិក្សាមាន៣២,៥ភាគរយ បានបញ្ចប់ថ្នាក់បឋមសិក្សាមាន២៧,៨ភាគរយបានបញ្ចប់មធ្យមសិក្សាបឋមភូមិមាន១៤,០ភាគរយ បានបញ្ចប់មធ្យមសិក្សាទុតិយភូមិមាន៦,៨ភាគរយ និងបានបញ្ចប់ថ្នាក់មហាវិទ្យាល័យមាន៥,៤ភាគរយ (អង្កេតស្តីពីសេដ្ឋកិច្ច សង្គមកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ២០១៦)។ លើសពីនេះទៀត នៅឆ្នាំ២០០៨ សហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជាបានរកឃើញថា អ្នកដែលធ្វើការដោយ

កម្លាំងកាយត្រូវបានកត់សម្គាល់ថាខ្វះជំនាញទន់ក្នុងការបំពេញការងារ។ ចំណែកបុគ្គលិកខ្លះដែលមានចំណេះដឹងបច្ចេកទេស ខ្វះបំណិនប្រាស្រ័យទាក់ទង បំណិនធ្វើសេចក្ដីសម្រេច និងបំណិនដោះស្រាយបញ្ហា។

រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ ដែលត្រូវរុញច្រានដោយកម្លាំងពលកម្មដែលមានទាំងចំណេះដឹងបច្ចេកទេសកម្រិតខ្ពស់និងបំណិនអរូបវន្ត។

ការប្រែប្រួលសង្គម សេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ ឧស្សាហកម្ម និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានតម្រូវឱ្យមានការធ្វើបច្ចុប្បន្នកម្ម និងកែលម្អកម្មវិធីអក្ខរកម្មដែលសង្កត់ធ្ងន់ទៅលើការចេះអក្សរនិងលេខ ទៅជាកម្មវិធីសិក្សាពេញមួយជីវិតដែលសង្កត់ធ្ងន់លើបំណិនបច្ចេកទេសវិជ្ជាជីវៈ បំណិនអាជីព និងបំណិនអរូបវន្ត ដែលអ្នកសិក្សាអាចសិក្សានៅគ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយ ជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់គាំទ្រសកម្មភាពសិក្សា។

គោលនយោបាយអប់រំក្រៅប្រព័ន្ធឆ្នាំ២០០២ បានរួមចំណែកសម្រេចលទ្ធផលខាងលើនេះ តាមរយៈការផ្ដល់ការអប់រំគ្រប់រូបភាព។ វិសាលភាពគោលនយោបាយនេះ នៅមិនទាន់អាចឆ្លើយតបបានទៅនឹងបរិបទនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់ប្រទេស ទោះបីមានភាពស៊ីចង្វាក់គ្នាទៅនឹងបញ្ញត្តិនៃការសិក្សាពេញមួយជីវិតយ៉ាងណាក៏ដោយ។ គោលនយោបាយអប់រំក្រៅប្រព័ន្ធឆ្នាំ២០០២ តម្រូវឱ្យធ្វើបច្ចុប្បន្នកម្ម ដោយត្រូវពង្រីកវិសាលភាព និងយន្តការមួយចំនួនឱ្យកាន់តែប្រសើរថែមទៀត។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនិងចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡាបានផ្ដួចផ្ដើមអភិវឌ្ឍគោលនយោបាយជាតិស្ដីពីការសិក្សាពេញមួយជីវិត សំដៅបង្កើនការអភិវឌ្ឍធនធានមនុស្សដែលមានសក្ដានុពលឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គោលនយោបាយនេះ ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីគ្រប់ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដោយផ្ដោតលើការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព និងគុណសម្បទា។ គោលនយោបាយជាតិស្ដីពីការសិក្សាពេញមួយជីវិតអាចជាយន្តការប្រទាក់ក្រឡាក្នុងគោលដៅរួមមួយ ដែលអាចបើកទូលាយឱ្យមានការចូលរួមបានកាន់តែប្រសើរឡើង និងកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងការផ្ដល់ឱកាស និងសេវា ព្រមទាំងមានការទទួលស្គាល់ និងឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទទួលសេវា ក៏ដូចជាទីផ្សារការងារ ជាពិសេស ដល់ក្រុមដែលបាត់បង់ឱកាស។

## ២. ចក្ខុវិស័យ

គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិតមានចក្ខុវិស័យ អភិវឌ្ឍប្រជាជនកម្ពុជាគ្រប់រូបឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា ដើម្បីរួមចំណែកបង្កើនសេដ្ឋកិច្ច និងលើកកម្ពស់សុខដុមជីវិតបុគ្គល គ្រួសារ និងសង្គម តាមរយៈការផ្តល់ឱកាសសិក្សាពេញមួយជីវិត គ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយ។

## ៣. គោលបំណង

គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិតមានគោលបំណងផ្តល់ឱកាស និងគាំទ្រឱ្យប្រជាជនគ្រប់រូបទទួលបានការសិក្សាតាមគ្រប់រូបភាពនិងប្រើប្រាស់ចំណេះដឹង តាមជំនាញដែលទទួលបានដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ និងប្រាក់ចំណូល ស្របតាមយុគសម័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងសង្គមពុទ្ធិ។

## ៤. គោលដៅ

ដើម្បីសម្រេចចក្ខុវិស័យនិងគោលបំណងខាងលើ ត្រូវកំណត់គោលដៅដូចខាងក្រោម៖

៤.១. ផ្តល់សេវាការសិក្សាពេញមួយជីវិតដល់ប្រជាជនកម្ពុជាគ្រប់រូប។

៤.២. អភិវឌ្ឍកម្មវិធីសិក្សាពេញមួយជីវិតឱ្យសម្បូរបែបនិងមានភាពបត់បែន ឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សា។

៤.៣. អភិវឌ្ឍមជ្ឈមណ្ឌលសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងទីកន្លែងសិក្សាឱ្យបានសមស្រប។

៤.៤. បណ្តុះបណ្តាលអ្នកសម្របសម្រួលកម្មវិធីសិក្សាពេញមួយជីវិត ប្រកបដោយវិជ្ជាជីវៈ។

៤.៥. ផ្តល់ការទទួលស្គាល់ ការបញ្ជាក់សុពលភាព និងមានការទទួលស្គាល់គុណភាពចំណេះដឹង ជំនាញ និងសមត្ថភាពនៃការសិក្សាពេញមួយជីវិតស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាដោយតម្លាភាព យុត្តិធម៌ និងមានសង្គតិភាព។

៤.៦. ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍ ផ្តល់ការគាំទ្រ និងអនុវត្តការសិក្សាពេញមួយជីវិត។

## ៥. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រសំខាន់ៗខាងក្រោមត្រូវបានកំណត់ក្នុងការអនុវត្ត ដើម្បីសម្រេចនូវគោលបំណងនិងគោលដៅខាងលើ៖

### ៥.១. អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ

- អភិវឌ្ឍនិងពង្រឹងបទដ្ឋានគតិយុត្ត ដើម្បីធានាការអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិតបានពេញលេញនៅគ្រប់ទីកន្លែង

- អភិវឌ្ឍយន្តការដឹកនាំ គ្រប់គ្រង និងអនុវត្តឱ្យមានគុណភាពនិងប្រសិទ្ធភាព
- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃដែលមានស្រាប់ ឱ្យមានលក្ខណៈប្រមូលផ្ដុំ សង្គតិភាព និងប្រសិទ្ធភាព ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

## ៥.២_ ផ្ដល់សេវាការសិក្សាពេញមួយជីវិតដល់ពលរដ្ឋគ្រប់រូប

- បណ្ដុះវប្បធម៌សិក្សាពេញមួយជីវិតនិងសិទ្ធិទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា នៅគ្រប់បណ្ដាអង្គភាព គ្រឹះស្ថាន រោងចក្រ សហគ្រាស ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ផ្ដល់សេវាអប់រំក្នុងប្រព័ន្ធ អប់រំក្រៅប្រព័ន្ធ និងមិនផ្លូវការដល់ពលរដ្ឋគ្រប់រូប ឱ្យទទួលបានអក្ខរពុទ្ធិ លេខពុទ្ធិ បំណិនបច្ចេកទេសវិជ្ជាជីវៈ បំណិនអាជីព និងបំណិនអរូបវន្ត
- ផ្ដល់ឱកាសឱ្យប្រជាជនកម្ពុជាគ្រប់រូបនិងអ្នកទទួលសេវា ទទួលបានព័ត៌មានអំពីសេវានិងចំណេះដឹងពីកម្មវិធីសិក្សាពេញមួយជីវិត
- បង្កើនការផ្សព្វផ្សាយអំពីភាពជោគជ័យនិងអ្នកទទួលបានផលប្រយោជន៍ពីការសិក្សាពេញមួយជីវិត
- ពង្រីកសេវារដ្ឋ ឯកជន សហគមន៍ តាមផ្ទះ ពិសេស បង្កើនឱកាសដល់យុវជននិងជនពេញវ័យដើម្បីអភិវឌ្ឍបំណិនវិជ្ជាជីវៈពេញមួយជីវិត
- បង្កើតឱកាសរៀននិងបរិស្ថានរៀនសូត្រសម្រាប់ការអប់រំក្រៅប្រព័ន្ធដែលផ្ដល់ការអប់រំពេញមួយជីវិត
- លើកកម្ពស់របៀបរៀនសូត្រដែលមានភាពទន់ភ្លន់ បត់បែន ទាំងការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ និងមានការទទួលស្គាល់សុពលភាព
- ជំរុញការអនុវត្តកម្មវិធីស្ពានចម្លងបន្តជំនាញ
- ផ្ដល់ការប្រឹក្សាយោបល់ ការណែនាំអំពីអាជីពការងារនិងជំនាញវិជ្ជាជីវៈ និងការផ្សព្វផ្សាយអំពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។

## ៥.៣_ អភិវឌ្ឍកម្មវិធីសិក្សាពេញមួយជីវិតឱ្យសម្បូរបែបនិងមានភាពបត់បែនឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សា

- ធ្វើបច្ចុប្បន្នកម្មនិងវិសិដ្ឋកម្មកម្មវិធីសិក្សាអប់រំក្នុងប្រព័ន្ធ អប់រំក្រៅប្រព័ន្ធ និងអប់រំមិនផ្លូវការឱ្យសម្បូរបែប និងមានភាពបត់បែន ដើម្បីឱ្យអ្នកសិក្សាទទួលបានជំនាញ សមត្ថភាព គុណតម្លៃ វប្បធម៌ ចំណេះដឹង បញ្ញាយេនឌ័រ ឥរិយាបថសិក្សា និងឆ្លើយតបតម្រូវការសង្គម
- ធ្វើបច្ចុប្បន្នកម្មនិងវិសិដ្ឋកម្មសម្ភារៈបង្រៀននិងរៀន ឱ្យមានសង្គតិភាពស្របតាមនិន្នាការវិវត្តរបស់សង្គម សេដ្ឋកិច្ច
- ស្រាវជ្រាវ កសាង និងអនុវត្តគម្រោងកម្មវិធីនានា ស្របតាមទស្សនាទានការសិក្សាពេញមួយជីវិត

- លើកកម្ពស់កម្មវិធីអក្ខរកម្ម កម្មវិធីសមមូល និងកម្មវិធីកែលម្អគុណភាពនៃជីវិតឱ្យមានគុណភាពឆ្លើយតបនឹងតម្រូវការអ្នកសិក្សា
- លើកកម្ពស់កម្មវិធីតាមបែបចូលរួមរបស់អ្នកសិក្សានិងគ្រូបង្រៀន ដើម្បីអនុវត្តការរៀនសូត្រ និងបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ
- ជំរុញអភិវឌ្ឍទម្រង់ផ្សេងៗគ្នានៃការបណ្តុះបណ្តាលដែលមានមូលដ្ឋានបែបការងារថ្នាក់រៀននិងការរៀនសូត្រនៅកន្លែងសមស្រប
- បង្កើតកម្មវិធីបណ្តុះបណ្តាលសិក្សាពេញមួយជីវិតលើជំនាញបច្ចេកទេសនិងបំណិនអរូបវន្ត
- បង្កើតនិងអនុវត្តកម្មវិធីសិក្សាពេញមួយជីវិត នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

## ៥.៤- អភិវឌ្ឍមជ្ឈមណ្ឌលសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងទីកន្លែងសិក្សាឱ្យបានសមស្រប

- រៀបចំទីកន្លែងសាធារណៈជាទីកន្លែងសម្រាប់ការសិក្សាពេញមួយជីវិត
- រៀបចំហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសិក្សាឱ្យបានសមស្រប ដើម្បីធានាឱ្យបានការងារប្រព្រឹត្តទៅបានល្អ មាននិរន្តរភាព និងប្រសិទ្ធភាព
- បង្កើតមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត រួមទាំងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងប្រើប្រាស់ទស្សនាទាននៃការសិក្សាពេញមួយជីវិតនៅតាមគ្រឹះស្ថានសិក្សា
- ផ្គត់ផ្គង់សម្ភារៈបម្រើការសិក្សាពេញមួយជីវិត
- រៀបចំសម្ភារៈបរិក្ខារអប់រំឱ្យឆ្លើយតបទៅនឹងតម្រូវការអ្នកសិក្សាមានពិការភាព និងការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ
- ផ្តល់បរិយាកាសសិក្សាដែលមានសុវត្ថិភាព អហិង្សា និងបរិយាបន្នប្រកបដោយប្រសិទ្ធភាពសម្រាប់ទាំងអស់គ្នា
- ជំរុញសហគមន៍ឱ្យចូលរួមក្នុងដំណើរការរៀបចំទីកន្លែងសិក្សាពេញមួយជីវិត
- ធានាឱ្យថ្នាក់រៀន កន្លែងសិក្សា និងមជ្ឈមណ្ឌលសិក្សាមានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ និងមានបច្ចេកវិទ្យាសមស្រប
- រៀបចំនិងធានាឱ្យមជ្ឈមណ្ឌលវាយតម្លៃផ្អែកលើសមត្ថភាព មានធនធានសម្រាប់ផ្តល់សេវាវាយតម្លៃសមត្ថភាពប្រកបដោយគុណភាព ស្របតាមបច្ចេកវិទ្យា និងលក្ខខណ្ឌតម្រូវការនៃទីផ្សារការងារ/ប្រព័ន្ធធានាគុណភាព។

## ៥.៥- បណ្តុះបណ្តាលអ្នកសម្របសម្រួលកម្មវិធីសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាជីវៈ

- ជំរុញការបណ្តុះបណ្តាល តម្រង់ទិសការអនុវត្ត ឱ្យមានការយល់ដឹងពីវិធីសាស្ត្របង្រៀននិងកម្មសិក្សាប្រតិបត្តិ
- អភិវឌ្ឍសមត្ថភាពដល់អ្នកផ្តល់សេវាអំពីបំណិនជំនាញមុខរបរផ្សេងៗ ជំនាញវិជ្ជាជីវៈ ដើម្បីធានាដំណើរការនៃការសិក្សាពេញមួយជីវិតប្រកបដោយគុណភាព និងប្រសិទ្ធភាព

- លើកកម្ពស់សមត្ថភាពគ្រូតាមរយៈការបណ្តុះបណ្តាល និងតម្រង់ទិសមុនឬក្នុងពេលអនុវត្តកម្មវិធីលើវិធីសាស្ត្របង្រៀននិងកម្មសិក្សាប្រតិបត្តិ
- លើកកម្ពស់សមត្ថភាពអ្នកវាយតម្លៃផ្អែកលើសមត្ថភាព តាមរយៈការបណ្តុះបណ្តាលទាំងវិធីសាស្ត្រវាយតម្លៃសមត្ថភាព និងជំនាញបច្ចេកវិទ្យា។

## ៥.៦. ផ្តល់ការទទួលស្គាល់ ការបញ្ជាក់សុពលភាព និងមានការទទួលស្គាល់គុណភាពនៃការសិក្សាពេញមួយជីវិតដោយតម្លាភាព យុត្តិធម៌ និងមានសង្គតិភាព

- បង្កើតយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់វិញ្ញាបនបត្រឬលិខិតទទួលស្គាល់ដល់អ្នកអនុវត្តកម្មវិធី
- ជំរុញនិងទទួលស្គាល់ការសិក្សាដែលមានពីមុននិងសមត្ថភាពនាពេលបច្ចុប្បន្ន
- បង្កើនការយល់ដឹងអំពីប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- បង្កើនឱកាសនិងការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយផ្តល់នូវជម្រើសផ្សេងៗមានភាពបត់បែន
- អភិវឌ្ឍក្របខណ្ឌវាយតម្លៃអក្ខរកម្មនិងឧបករណ៍នានា ដើម្បីវាយតម្លៃកម្រិតជំនាញផ្អែកលើលទ្ធផលសិក្សា
- ទទួលស្គាល់លទ្ធផលនិងសមត្ថភាពរបស់អ្នកទទួលសេវាការសិក្សាពេញមួយជីវិតតាមគ្រប់រូបភាព។

## ៥.៧. ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់គាំទ្រការសិក្សាពេញមួយជីវិត

- ចលនាក្រសួង ស្ថាប័នពាក់ព័ន្ធ អប់រំក្នុងប្រព័ន្ធ និងឧត្តមសិក្សា ដើម្បីគាំទ្រនិងលើកទឹកចិត្តដល់ប្រជាជនកម្ពុជាគ្រប់រូបឱ្យទទួលបានការសិក្សាពេញមួយជីវិត
- ពង្រឹងស្ថាប័ននៃការសិក្សាពេញមួយជីវិត ឱ្យមានការអភិវឌ្ឍប្រកបដោយគុណភាពនិងប្រសិទ្ធភាព
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកៀរគរការគាំទ្រទាំងផ្នែកធនធាននិងបច្ចេកទេស
- សម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍក្នុងការបង្កើតសង្គមពុទ្ធិ
- សហការនិងតាមដានកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បម្រើឱ្យការសិក្សាពេញមួយជីវិត
- ធានាថាការសិក្សាពេញមួយជីវិតត្រូវបានដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍ៥ឆ្នាំនិងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- លើកទឹកចិត្តបុគ្គលិកនិងនិយោជិតឱ្យបង្កើនគុណវុឌ្ឍិពីមួយកម្រិតទៅមួយកម្រិតស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ។

## ៥.៨. លើកកម្ពស់វប្បធម៌រស់នៅជាពលរដ្ឋសកល

- ចលនាពលរដ្ឋគ្រប់រូប ពិសេស យុវជនឱ្យចូលរួមក្នុងការងារស្ម័គ្រចិត្តតាមគ្រប់រូបភាព
- បណ្តុះវប្បធម៌ចែករំលែកចំណេះដឹង បទពិសោធ ដោយស្ម័គ្រចិត្ត ពីក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងសង្គមស៊ីវិល
- បង្កើនការទាក់ទាញ ជំរុញ និងលើកទឹកចិត្តដល់បុគ្គលិកស្ថាប័នរដ្ឋនិងឯកជនឱ្យអនុវត្តការសិក្សាពេញមួយជីវិត
- លើកទឹកចិត្តឱ្យពលរដ្ឋគ្រប់រូប ពិសេស ក្រុមជនបាត់បង់ឱកាសបានចូលរួមនិងបានទទួលផលប្រយោជន៍ពីកម្មវិធីសិក្សាពេញមួយជីវិត
- បង្កើនឱកាសទទួលបានការងារធ្វើសម្រាប់អ្នកដែលបានឆ្លងកាត់ប្រព័ន្ធបណ្តុះបណ្តាលច្បាស់លាស់ ដោយលើកទឹកចិត្ត និងផ្តល់អាទិភាពដល់អ្នកធ្វើការងារស្ម័គ្រចិត្ត
- លើកទឹកចិត្តដល់គ្រួសារ សហគមន៍ ឱ្យស្រឡាញ់ការសិក្សាពេញមួយជីវិត លុបបំបាត់ការរើសអើងគ្រប់រូបភាព និងរស់នៅប្រកបដោយសុខដុម។

## ៥.៩. លើកកម្ពស់សមភាព សមធម៌ យេនឌ័រ និងបរិយាបន្ន

- បង្កឱកាសដល់ក្រុមជនបាត់បង់ឱកាសទទួលបានការសិក្សាពេញមួយជីវិត
- ផ្តល់អាទិភាពដល់សិស្សដែលបានបោះបង់ការសិក្សា ក្រុមជនងាយរងគ្រោះ ជនជាតិដើមភាគតិច ពលករចំណាកស្រុក អ្នកគ្មានការងារ និងក្រុមបាត់បង់ឱកាសដើម្បីទទួលបានជំនាញមុខរបរងាយៗ ជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ
- បង្កើតឱកាសនិងស្តារនីតិសម្បទាដល់ជនរងគ្រោះ តាមរយៈការផ្តល់ជំនាញវិជ្ជាជីវៈនិងជំនាញមុខរបរងាយៗ
- ជំរុញសមភាពយេនឌ័រនិងបរិយាបន្នក្នុងដំណើរការសិក្សាពេញមួយជីវិត។

## ៥.១០. លើកកម្ពស់ការអប់រំតាមប្រព័ន្ធបច្ចេកវិទ្យា

- ផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងពីគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត
- ផ្តល់ព័ត៌មានតាមបណ្តាញផ្សព្វផ្សាយជាប្រចាំ ពាក់ព័ន្ធនឹងចំណេះដឹងវិជ្ជាជីវៈ បច្ចេកទេស វិទ្យាសាស្ត្រ អប់រំ វប្បធម៌ សាសនា និងបណ្តាព័ត៌មានផ្សេងៗទៀត
- ជំរុញនិងរៀបចំអត្ថបទមេរៀន ជំនាញមុខរបរ ជំនាញវិជ្ជាជីវៈ បទពិសោធផ្សេងៗ និងអត្ថបទអប់រំ សម្រាប់ការអប់រំពេញមួយជីវិត តាមប្រព័ន្ធបច្ចេកវិទ្យា
- ជំរុញការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ការបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេស បច្ចេកវិទ្យាចល័ត សម្រាប់កម្មវិធីអប់រំផ្សេងៗ។

### ៥.១១. ជំរុញវិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមផ្តល់សេវាសិក្សាពេញមួយជីវិត

- លើកទឹកចិត្តម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ សិប្បកម្ម កសិដ្ឋាន និងវិស័យឯកជនផ្សេងទៀត ឱ្យឧបត្ថម្ភ គាំទ្រ និងចូលរួមសិក្សាពេញមួយជីវិត
- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ គាំទ្រការសិក្សាពេញមួយជីវិត
- កសាងបណ្តាញការងារជាមួយអ្នកផ្តល់សេវាក្នុងតំបន់ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍកម្មវិធីសិក្សាពេញមួយជីវិត
- សហការនិងគាំទ្រការផ្តួចផ្តើមជាមួយមាតាបិតានិងសហគមន៍ ឱ្យមានកម្មវិធីសិក្សាពេញមួយជីវិត
- ជំរុញសហគ្រាស គ្រឹះស្ថាន ឱ្យផ្តល់ និងបង្កើតឱកាសដល់កម្មករ និយោជិត ឱ្យទទួលបានការសិក្សាពេញមួយជីវិត
- លើកកម្ពស់កម្មវិធីសិក្សាពេញមួយជីវិត ដោយសហការជាមួយសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកផ្តល់សេវានានា
- ពង្រឹងនិងពង្រីកសហគ្រិនភាពដល់ក្រុមគោលដៅ។

## ៦. ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ ផែនការដែលត្រូវអនុវត្តចាំបាច់រួមមាន៖

### ៦.១. ការបង្កើតយន្តការ

- បង្កើតគណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត។

### ៦.២. ការបង្កើតក្របខណ្ឌគតិយុត្ត

- គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រីឬឧបនាយករដ្ឋមន្ត្រីដែលជាប្រធាន និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាជាអនុប្រធានប្រចាំការ
- ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត ត្រូវកំណត់ដោយព្រះរាជក្រឹត្យ
- គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិតត្រូវកំណត់និងប្រើប្រាស់យន្តការដែលមានស្រាប់ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- កសាងបទដ្ឋានគតិយុត្ត។

### ៦.៣- ការគាំទ្រហិរញ្ញវត្ថុ

ដើម្បីគាំទ្រយន្តការនិងដំណើរការសកម្មភាពតាមយុទ្ធសាស្ត្រនីមួយៗ គោលនយោបាយនេះត្រូវមានថវិកាដែលបានមកពីប្រភព៖

- ថវិការបស់ក្រសួងទទួលបន្ទុកវិស័យអប់រំនិងក្រសួងពាក់ព័ន្ធ
- ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- ថវិកាដៃគូអភិវឌ្ឍ វិភាគទានពីវិស័យឯកជន សហគមន៍ ព្រមទាំងថវិកាមកពីប្រភពផ្សេងៗទៀត។

### ៦.៤- ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលធនធានមនុស្សលើការងារគ្រប់គ្រង ការរៀបចំផែនការ ការសម្របសម្រួល ការធ្វើបច្ចុប្បន្នកម្ម និងកែលម្អកម្មវិធីសិក្សាអប់រំក្នុងប្រព័ន្ធ អប់រំក្រៅប្រព័ន្ធ និងអប់រំមិនផ្លូវការឱ្យសម្បូរបែប និងមានភាពបត់បែន តាមគ្រប់រូបភាពសំដៅលើកកម្ពស់ការសិក្សាពេញមួយជីវិត។

### ៦.៥- ដំណើរការអនុវត្តគម្រោង

រៀបចំផែនការសកម្មភាពជាតិស្តីពីការសិក្សាពេញមួយជីវិតរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដោយមានការសិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធ ដើម្បីទទួលបានការគាំទ្រនិងធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត។ ផែនការនេះ ត្រូវឆ្លុះបញ្ចាំងពីចក្ខុវិស័យរាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់ការសិក្សាពេញមួយជីវិតរបស់ប្រជាជនកម្ពុជានិងឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ព្រមទាំងត្រូវអនុវត្តនៅក្នុងក្របខណ្ឌកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។

## ៧- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិតឱ្យមានគុណភាពនិងប្រសិទ្ធភាព ចាំបាច់ត្រូវមានប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ការពិនិត្យឡើងវិញ និងសំណើកែលម្អការអនុវត្តដោយផ្តោតលើ៖

- គោលដៅនិងយុទ្ធសាស្ត្រនៃគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត
- សូចនាករនៃផែនការសកម្មភាពជាតិស្តីពីការសិក្សាពេញមួយជីវិត
- ការចូលរួមរបស់អ្នកទទួលសេវា អ្នកផ្តល់សេវា និងភាគីពាក់ព័ន្ធ
- របាយការណ៍វឌ្ឍនភាពនៃការសិក្សាពេញមួយជីវិត

- លទ្ធផលដែលទទួលបានធៀបនឹងចំណុចដៅ
- របាយការណ៍ពិនិត្យឡើងវិញស្តីពីការអនុវត្តការសិក្សាពេញមួយជីវិត
- ផលប្រយោជន៍ដែលទទួលបានពីការអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត។

## ៨. សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ជាផែនទីបង្ហាញផ្លូវសម្រាប់អភិវឌ្ឍសង្គមនិងធនធានមនុស្ស ឆ្ពោះទៅកាន់សុខសន្តិភាពនិងការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីសម្រេចបាននូវគោលនយោបាយនេះ ទាមទារឱ្យក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់មានកិច្ចសហការនិងគាំទ្រដោយយកចិត្តទុកដាក់ខ្ពស់។ ជាងនេះទៅទៀត គោលនយោបាយតម្រូវឱ្យមានយន្តការនិងបទដ្ឋានគតិយុត្ត ដើម្បីបង្កើតក្រុមឬអង្គភាពគាំទ្រ ក្នុងការសម្របសម្រួលការងារ ការធ្វើផែនការយុទ្ធសាស្ត្រជាតិ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងការកៀរគរជំនួយពីគ្រប់មជ្ឈដ្ឋាន សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត។

គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ជំរុញឱ្យប្រជាជនកម្ពុជាក្លាយជាប្រជាពលរដ្ឋសកលស្របតាមតម្រូវការសង្គមនិងនិន្នាការវិវត្តរបស់សកលលោក ពិសេសបរិបទទីផ្សារការងារដែលត្រូវការវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា។ បុគ្គលម្នាក់ៗត្រូវអភិវឌ្ឍទាំងជំនាញរឹងនិងជំនាញទន់ ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងលើកកម្ពស់គុណភាពនៃជីវិតនៅក្នុងបរិបទសង្គមពុទ្ធិ។

# សទ្ទានុក្រម

**កម្មវិធីស្ពានចម្លង** គឺជាកម្មវិធីសំខាន់ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ស្ពានចំណេះដឹងឬវិលទៅរកការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឱ្យពួកគេវិលត្រឡប់ទៅសាលារៀនមានជំនាញថ្មី សំដៅលើកកម្ពស់ចំណេះដឹង បង្កើនប្រាក់ចំណូល និងកសាងអាជីពការងារសមរម្យនៅពេលអនាគត។

**ក្របខណ្ឌគុណវុឌ្ឍិជាតិ** សំដៅដល់លិខិតូបករណ៍សម្រាប់ធ្វើការអភិវឌ្ឍនិងចំណាត់ថ្នាក់គុណវុឌ្ឍិ ដោយអាស្រ័យទៅនឹងកម្រងលក្ខណវិនិច្ឆ័យនៃការសិក្សាដែលសម្រេចបានតាមកម្រិតនីមួយៗ ដោយកម្រងលក្ខណវិនិច្ឆ័យនោះបានបញ្ជាក់ជាលក្ខណៈទូទៅ នៅក្នុងការពណ៌នាគុណវុឌ្ឍិ ក្នុងកម្រិតនីមួយៗនៃក្របខណ្ឌគុណវុឌ្ឍិ។

**កាយសម្បទា** សំដៅដល់រូបរាងកាយពេញលេញនិងសុខភាពរឹងមាំល្អ។

**គុណសម្បទា** សំដៅដល់ការបរិបូរណ៍ដោយសេចក្តីល្អ សេចក្តីបរិសុទ្ធ។

**ចរិយាសម្បទា** សំដៅដល់អត្តចរិត មនោសញ្ចេតនា ដែលសិស្សានុសិស្សត្រូវចេះប្រកាន់យកក្នុងស្ថានភាពជាក់ស្តែងមួយ ដើម្បីដាក់ចេញនូវវិធានការឬដំណោះស្រាយសមស្របនិងស្មើភាពជាមួយដៃគូ។

**ជំនាញទន់/បំណិនអរូបវន្ត** សំដៅដល់ជំនាញមិនមែនបច្ចេកទេសដែលបុគ្គលម្នាក់ៗត្រូវការចាំបាច់ដើម្បីប្រតិបត្តិការងារឱ្យត្រូវតាមតម្រូវការក្នុងកន្លែងការងារនិងសង្គម ដែលជំនាញទាំងនេះអាចផ្ទេរនិងយកទៅអនុវត្តនៅគ្រប់ការងារ និងឧស្សាហកម្មទៅតាមកម្រិតដែលគេបានកំណត់។

**ជំនាញរឹង** សំដៅដល់ជំនាញបច្ចេកទេសដែលបុគ្គលម្នាក់ៗត្រូវការចាំបាច់ ដើម្បីប្រតិបត្តិការងារឱ្យត្រូវតាមតម្រូវការក្នុងកន្លែងការងារនិងសង្គម ដែលជំនាញទាំងនេះអាចផ្ទេរនិងយកទៅអនុវត្តនៅគ្រប់ការងារ និងឧស្សាហកម្មទៅតាមកម្រិតដែលគេបានកំណត់។

**បំណិនសម្បទា** សំដៅដល់ភាពប៉ិនប្រសប់ ដែលសិស្សានុសិស្សទទួលបានពីកម្មវិធីអប់រំហើយអាចយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួនបាន។

**វិជ្ជាសម្បទា** សំដៅដល់ចំណេះដឹងដែលសិស្សានុសិស្សទទួលបានពីកម្មវិធីអប់រំ ហើយអាចយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួនបាន។

**ការអប់រំបរិយាបន្ន** សំដៅដល់ដំណើរការដោះស្រាយនិងឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្សេងៗគ្នារបស់បុគ្គលនិងក្រុមនានាតាមរយៈការលើកកម្ពស់ការចូលរួមក្នុងការសិក្សា វប្បធម៌ និងសហគមន៍ និងការកាត់បន្ថយ និងលុបបំបាត់ការបំភ្លេចចោលឬផាត់ចេញពីប្រព័ន្ធអប់រំ។ ការអប់រំនេះទាមទារឱ្យមានការផ្លាស់ប្តូរនិងកែសម្រួលខ្លឹមសារមេរៀន យុទ្ធវិធី ទម្រង់ និងយុទ្ធសាស្ត្រដើម្បីបញ្ចូលជនគ្រប់រូបទៅក្នុងប្រព័ន្ធអប់រំ។ ការអប់រំបរិយាបន្ន គឺជាដំណើរការពង្រឹកសមត្ថភាពរបស់ប្រព័ន្ធអប់រំក្នុងការផ្តល់សេវាកម្មដល់អ្នកសិក្សាគ្រប់រូប។